# សិក្ខាបទ ៥

## បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក
កិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ។

## អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក
កិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយឬដោយវាចា ។

## កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក
កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

## មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក
កិរិយាពោលនូវពាក្យកុហក ។

## សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុ
ជាទីតាំងនៃសេចក្តីប្រមាទគឺផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ។

ដកស្រង់និងចងក្រងដោយខ្ញុំបាទ **ទ៉ាន់ អ៊ុន** អាចារ្យទី១សម្រាប់វត្តធម្មរាម ក្រុងស្តុកតុន រដ្ឋកាលីហ្វរនីញ៉ា ព.ស.២៥៤៣
វាយចម្លងដាក់គេហទំព័រវត្ត ដោយខ្ញុំព្រះករុណាខ្ញុំបាទ **អ៊ិន លី** ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២

វត្តធម្មរាម
វត្តធម្មរាម